# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និង បំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរ
- បានឃើញអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិរៀបចំវចនានុក្រមភាសាខ្មែរ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណព្វ** | ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ | ប្រធាន |
| ២- ឯកឧត្តម **សូ មុយឃៀង** | អនុប្រធានអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិភាសាខ្មែរ | អនុប្រធាន |



www.pheakdeylaw.com

| | | |
|---|---|---|
| ៣- ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រុំ ម៉ល់ | ទីប្រឹក្សាជាន់ខ្ពស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ | ទីប្រឹក្សា |
| ៤- ព្រឹទ្ធាចារ្យអគ្គបណ្ឌិត ប៊ុត សារង្ស | ទីប្រឹក្សាក្រុមប្រឹក្សាជាតិភាសាខ្មែរ | ទីប្រឹក្សា |
| ៥- ឯកឧត្តមបណ្ឌិត ហ៊ាន សាហ៊ីប | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម ឈន អៀម | អនុប្រធានក្រុមប្រឹក្សាជាតិភាសាភាសាខ្មែរ | សមាជិក |
| ៧- ឯកឧត្តម ច័ន្ទ មេត្តពល | អនុប្រធានប្រចាំការក្រុមប្រឹក្សាជាតិភាសាភាសាខ្មែរ | សមាជិក |
| ៨- លោកបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- លោកបណ្ឌិត នន ដារ៉ា | សាស្ត្រាចារ្យភាសាវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០- លោក យៀង វីរបុត្រ | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ ជំនាញសិលាចារឹក នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១១- លោក អែម ឧត្តម | ព្រឹទ្ធបុរសរងពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេសនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ | សមាជិក |
| ១២- លោក អោ សៀម | ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៣- លោក ផាន់ គីមសឿន | សាស្ត្រាចារ្យភាសាវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១៤- លោក សំ លាងអេង | សាស្ត្រាចារ្យភាសាវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១៥- លោក សយ ចន្ទី | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៃវិទ្យាល័យបុសខ្នុរ | សមាជិក |
| ១៦- លោក សេក ណាន | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៃវិទ្យាល័យហ៊ុនសែនក្រាំ | សមាជិក |
| ១៧- លោក អ៊ុំ ខឿនបញ្ញារិទ្ធិ | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៃវិទ្យាល័យនេតយ៉ង់ | សមាជិក |
| ១៨- លោក ប៉ូ ម៉េងឃី | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៃវិទ្យាល័យ សម្ដេចតេជោហ៊ុនសែនស្ទឹងត្រង់ | សមាជិក |
| ១៩- លោក ញឹប សំណាង | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៃវិទ្យាល័យ សម្ដេចតេជោហ៊ុនសែនស្ទឹងត្រង់ | សមាជិក |
| ២០- លោក ខាត់ ភួក | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៃវិទ្យាល័យ សម្ដេចតេជោហ៊ុនសែនស្ទឹងត្រង់ | សមាជិក |
| ២១- លោក គី ចាន់ធូ | សាស្ត្រាចារ្យភាសាវិទ្យានៃវិទ្យាល័យ សម្ដេចតេជោហ៊ុនសែនស្ទឹងត្រង់ | សមាជិក |
| ២២- លោក ប៊ុន សុខន | សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៃវិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនស្ដី | សមាជិក |
| ២៣- លោកស្រីបណ្ឌិត ហង់ ថាវី | មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា | លេខាទទួលបន្ទុកហិរញ្ញកិច្ច។ |

**ប្រការ២.-**

គណៈកម្មាធិការរៀបចំវចនានុក្រមភាសាខ្មែរនេះ មានភារកិច្ចរៀបចំវចនានុក្រមភាសាខ្មែរដោយឈរលើស្មារតីអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរ។



www.pheakdeylaw.com

**ប្រការ៣.-**

ប្រធានគណៈកម្មការ មានសិទ្ធិអញ្ជើញសមាជិកចូលរួមប្រជុំតាមការចាំបាច់។

ប្រធានគណៈកម្មាធិការនេះ មានសិទ្ធិបង្កើតគណៈកម្មការជំនាញផ្សេងៗតាមការចាំបាច់។

ប្រធានគណៈកម្មាធិការនេះ មានសិទ្ធិតែងតាំងអ្នកជំនាញភាសាវិទ្យា និង/ឬ អក្សរសាស្ត្រខ្មែរមួយចំនួនតាមការចាំបាច់។

**ប្រការ៤.-**

គណៈកម្មាធិការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ និងមានកញ្ចប់ថវិកាដោយឡែក ដូចមានចែងក្នុងលិខិតលេខ១២៣៧ សជណ.ផហ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com